អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# ប័ណ្ណណែនាំអំពីរបៀបដឹកនាំ <u>ការនិទានរឿង</u>

## <u>ការសិក្សាស្រាវជ្រាវ</u>

កុមារតូចៗបានឮសូរ និងពាក្យតាំងពីពួកគេកើតមក។ ពួកគេចាប់ផ្ដើមបង្កើតសូរដោយខ្លួនឯង និងប្រើប្រាស់សូរទាំងនោះដើម្បីស្វែងយល់ពីអត្ថន័យ។ មុនដំបូងពួកគេចាប់ផ្ដើមជាមួយនិងពាក្យពិតជាក់ស្ដែង។ ប្រសិនបើមនុស្សពេញវ័យ ឆ្លើយតបពាក្យទាំងនេះបានឆាប់រហ័សនោះពួកគេគឺបន្ថែមចំណេះដឹង និងពួកគេក្លាយជាផ្នែកមួយនៃការអភិវឌ្ឍន៍វាក្យសព្ទ។

កុមាររៀនយ៉ាងយកចិត្តទុកដាក់តាមរយៈការស្ដាប់រឿងនិទាន និងជាញឹកញាប់ពួកគេចូលរួមជាមួយនិងល្បះជាក់លាក់ណាមួយ ទោះបីពួកគេមិនអាចអានទាំងអស់ក៏ដោយ។ សាច់រឿងដែលមានពាក្យឬឃ្លាដដែលគឺមានសារៈសំខាន់ណាស់សម្រាប់មុមារតូចៗ។ កុមារតូចៗបានឮ និងព្យាយាមឲ្យពួកគេរៀនពីល្បះនិងប្រយោគវែងៗបន្ថែមទៀត។ ទាំងអស់នេះគឺជាប់ពាក់ព័ន្ធអភិវឌ្ឍចំណេះដឹងផ្នែកខាងវេយ្យករណ៍ ដែលធ្វើឲ្យអត្ថន័យរបស់វាកាន់ច្បាស់។ កុមារពង្រីកចំណេះរបស់ពួកគេលើ ពាក្យ និងយល់ពីពាក្យទាំងនោះតាមរយៈការស្ដាប់អំពីបទពិសោធន៍ អ្នកនិយាយពាក្យ និងតាមរយៈភាសារសប់ពួកគេផ្ទាល់។ នេះហើយគឺជាការអភិវឌ្ឍន៍ភាសា។ ការរៀនអំណានដែលជោគជ័យគឺអាស្រ័យលើជំនាញភាសាដ៏ល្អមួយ។ កុមារដែលមកពីគ្រួសារដែលមានការជជែកពិភាក្សាច្រើនមានធនធានសម្ភារអានច្រើនដូចជា សៀវភៅអាន កាសែត អត្ថបទព័ត៌មាន ។ល។ កុមារនោះនិងមានគុណសម្បត្តិនៅពេលពួកគេទៅសាលារៀន។

# សេចក្តីណែនាំសម្រាប់ ការនិទានរឿង

យើងចង់ឲ្យកុមារមានចំណាប់អារម្មណ៍ក្នុងការអាន។ ជាងនេះទៅទៀត ពួកគេនិងមានភាពកាក់តែសប្បាយរីករាយនៅពេលពួកគេត្រូវបានណែនាំឲ្យអានតាំងពីកុមារភាព។ សូមបីតែកុមារតូចៗមានភាពរីករាយក្នុងការស្តាប់រឿង នេះជាទម្រង់មូលដ្ឋានគ្រឹះនៃការអានរបស់ពួកគេដូចខាងក្រោម។

- ណែនាំសកម្មភាពទៅអ្នកស្តាប់ ប្រាប់ពួកគេអំពីចំណងជើងនៃរឿង។
- ប្រាកដថាពួកគេអាចមើលឃើញអ្នកច្បាស់
- ចូលចាំថាត្រូវធ្វើភ្នែកឲ្យមានការទាក់ទាញទៅអ្នកស្តាប់។
- ប្រើប្រាសរូបភាពដើម្បីឲ្យរឿងមានភាពរស់រវើក មានកាយវិការផ្លាស់ប្តូរការលើកដាក់សំឡេង មានវត្ថុជាក់ស្តែងបើអាច។
- រឿងល្អជាញឹកញយជារឿងដែលមានលក្ខខណដដែលៗ។
- រាល់ការនិទានឡើងវិញត្រូវមានភាពខុសគ្នា។
- ការស្តាប់ជាញឹកញយអាចរៀនបានអំពីពាក្យថ្មីដោយប្រើប្រាសពាក្យន័យដូចនៅក្នុងផ្នែកដែលធ្វើសារឡើងវិញ។
- ត្រូវមានសំណួរជាស្រេច ប្រសិនបើអ្នកចង់ឲ្យកុមារឆ្លើយ។
- ការនិទានរឿងមិនចាំបាច់មានការសរសេរឬអានទេ ប៉ុន្តែត្រូវការបង្ហាញកុមារអ្នកត្រូវសរសេរពាក្យខ្លះបើចាំបាច់នៅលើក្តាខៀន។
- អ្នកចង់ឲ្យកុមារនិទានផ្នែកណានៃរឿងមួយឡើងវិញឬគ្រប់ផ្នែកទាំងអស់ឬអ្នកនិទានឡើងវិញទាំងអស់។

អ្នកនិងមើលការបង្ហាញមួយរបស់គ្រូដូចមាននៅខាងក្រោមនេះ។

មានរឿងខ្លះជារឿងល្អសម្រាប់ធ្វើការនិទានដែលមាននៅក្នុងប្រភពធនធាន។

អានរឿងសារចុះសារឡើងមុនពេលអ្នកយករឿងនោះទៅនិទាន។

សូមឲ្យអ្នកប្រើប្រាស់រូបភាពនិងសម្ភារដែលមាននៅក្នុងប្រភពធនធាននោះ។

## ការនិទានរឿង

សូមចូលមើលវីដេអូតាមវេបសាយខាងក្រោម :

https://youtu.be/i2nCVqWLKCY

